**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៦.០៨៥/០៨ គ.ជ.ប.អគ្គ.ពត**

ភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៨

# ស្ថានីយវិទ្យុ FM93.5 MHz មានម៉ោងសម្រាប់លក់ឱ្យគណបក្សនយោបាយផ្សាយកម្មវិធីនយោបាយ

រហូតមកដល់ពេលនេះ គ.ជ.ប ទើបតែបានទទួលសេចក្តីជូនដំណឹងរបស់ស្ថានីយវិទ្យុមហានគរ **FM93.50MHz** មួយគត់ដែលបានប្រកាសលក់ម៉ោងចំនួន ៦៦០ នាទីក្នុងមួយថ្ងៃ ដល់គណបក្សនយោបាយទាំង ១១ ដែលមានបំណងទិញម៉ោងដើម្បីចាក់ផ្សាយអំពីគោលនយោបាយរបស់គណបក្សនយោបាយក្នុងការឃោសនាបោះឆ្នោត ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា នៅក្នុងអំឡុងពេល ៣០ថ្ងៃ នៃដំណើរការឃោសនាបោះឆ្នោត គណបក្សនយោបាយអាចផ្សព្វផ្សាយកម្មវិធីនយោបាយ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដែលរៀបចំឡើងដោយ គ.ជ.ប ។ ក្រៅពីនេះ គណបក្សនយោបាយអាចជួលម៉ោងផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយឯកជនបានផងដែរ ។ ឯកឧត្តមបានបញ្ជាក់ថា ចំពោះគោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជនក្នុងការលក់ម៉ោង ឬជួលម៉ោងចាក់ផ្សាយឱ្យគណបក្សនយោបាយ ដើម្បីចាក់ផ្សាយអំពីកម្មវិធីគោលនយោបាយក្នុងពេលឃោសនាបោះឆ្នោតនោះ គ.ជ.ប បានផ្សព្វផ្សាយរួចរាល់ហើយកាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៨ ។

លោក គង់ ចិត្រា នាយកប្រតិបត្តិនៃវិទ្យុមហានគរ **FM93.5 MHz** បានមានប្រសាសន៍ថា លោកបានជូនដំណឹងជាសាធារណៈអំពីការលក់ម៉ោងផ្សាយនេះ ហើយរហូតមកដល់ពេលនេះមានតែគណបក្សសិទ្ធិមនុស្សមួយគត់ ដែលបានធ្វើការទំនាក់ទំនងការជួលម៉ោងផ្សាយតាមរលកធាតុអាកាសនៃវិទ្យុរបស់លោក ។ តាមសេចក្តីប្រកាសព័ត៌មានរបស់វិទ្យុនេះ ដែលចេញផ្សាយនៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៨ បានឱ្យដឹងថា « ចំពោះគណបក្សនយោបាយ ដែលមានបំណងចង់ទិញម៉ោងសម្រាប់ធ្វើការឃោសនាលើរលកអាកាសស្ថានីយវិទ្យុមហានគរ **FM93.5 MHz** សូមធ្វើការទំនាក់ទំនងមកស្ថានីយយើងតាមទូរស័ព្ទលេខ: **០៩២ ៩១៣ ១១១ ឬ ០៩៩ ៩៩៩ ៩៧៩** នៅរៀងរាល់ម៉ោងធ្វើការ រហូតដល់កាលបរិច្ឆេទផុតកំណត់ នៃការលក់ម៉ោងចាក់ផ្សាយស្មើភាពនេះ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៨ វេលាម៉ោង ១៧ៈ ០០ ល្ងាច» ។

យោងតាមគោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ឯកជនក្នុងការលក់ម៉ោង ឬជួលម៉ោងចាក់ផ្សាយឱ្យគណបក្សនយោបាយដើម្បីចាក់ផ្សាយអំពីកម្មវិធីគោលនយោបាយក្នុងពេលឃោសនាបោះឆ្នោត លេខ១៣៦/០៨ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៨ ចំណុច ២.១ ចែងថា « ការលក់ម៉ោង ឬជួល ម៉ោងផ្សាយឱ្យគណបក្សនយោបាយធ្វើការផ្សព្វផ្សាយ អំពីគោលនយោបាយរបស់គណបក្សនយោបាយ ត្រូវផ្អែកទៅតាមគោលការណ៍ស្មើភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ » និងចំណុច ២.៥ ចែងថា « ការលក់ម៉ោងផ្សាយឬជួលម៉ោងផ្សាយឱ្យគណបក្សនយោបាយ មិនត្រូវអនុញ្ញាតឱ្យអ្នកគ្រប់គ្រងស្ថានីយវិទ្យុ និងទូរទស្សន៍លក់ម៉ោងផ្តាច់មុខឱ្យគណបក្សនយោបាយណាមួយឡើយ »។